# TriMet គោរពសិទ្ធិស៊ីវិល

TriMet ដំណើរការកម្មវិធីរបស់ខ្លួនដោយស្របទៅតាមច្បាប់ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត សាសនា ភេទ ចំណង់ចំណូលចិត្តផ្លូវភេទ ស្ថានភាពគ្រួសារ អាយុ ឬពិការភាពឡើយ ។

## សេចក្តីថ្លែងការណ៍ពីគោលនយោបាយរបស់ TriMet តាមច្បាប់ Title VI

Title VI នៃច្បាប់ស្តីពីសិទ្ធិស៊ីវិលនាឆ្នាំ 1964 ចែងថា៖

"គ្មាននរណាម្នាក់នៅក្នុងសហរដ្ឋអាមេរិក ដោយផ្អែកលើហេតុផលនៃពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើត នឹងត្រូវបានគេមិនអោយចូលរួម, បដិសេធជំនួយ ឬត្រូវទទួលរងនូវការរើសអើងក្នុងកម្មវិធីណាមួយ ឬសកម្មភាពណាមួយ ដែលកំពុងទទួលបានជំនួយហិរញ្ញវត្ថុពីសហព័ន្ធនោះឡើយ។"

TriMet ប្តេជ្ញាអនុវត្តតាមច្បាប់ Title VI សំរាប់កម្មវិធី និងសកម្មភាពនានាដែលទទួលមូលនិធិពីសហព័ន្ធ។ ដើម្បីស្នើសុំព័ត៌មានបន្ថែមស្តីពីតំរូវការនៃការមិនរើសអើងតាមច្បាប់ Title VI របស់TriMet សូមទូរស័ព្ទមកយើងខ្ញុំតាមលេខ **503-238-7433** (TTY 7-1-1) ឬអ៊ីមែល **administration@trimet.org**

## ដាក់ពាក្យបណ្តឹង Title VI

បុគ្គលណាដែលជឿថាខ្លួនបានទទួលរងនូវការធ្វើទុក្ខបុកម្នេញដោយការអនុវត្តរើសអើងខុសនឹងច្បាប់ Title VI អាចដាក់ពាក្យបណ្តឹងមក TriMet បាន។ រាល់បណ្តឹងតវ៉ាបែបនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងផ្ញើមក TriMet ក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការដែលមានភាពរើសអើងកើតឡើង។ សម្រាប់ព័ត៌មានស្តីពីនីតិវិធីដាក់ពាក្យបណ្តឹង សូមទាក់ទងទៅ TriMet តាមវិធីណាមួយដែលមានសរសេរខាងក្រោម។

TriMet<br>
Civil Rights Investigator<br>
1800 SW 1st Avenue, Suite 300<br>
Portland, OR 97201

ទូរស័ព្ទលេខ៖ **503-962-2217**<br>
ទូរសារលេខ៖ **503-962-2283**<br>
អ៊ីម៉ែល៖ **administration@TriMet.org**

អ្នកអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅរដ្ឋបាលសហព័ន្ធ នៅការិយាល័យសិទ្ធិស៊ីវិលបាន ដោយផ្ញើទៅ៖ Office of Civil Rights, Attention: Title VI Program Coordinator, East Building, 5th Floor-TCR, 1200 New Jersey Ave., SE, Washington, D.C. 20590.

TRIMET

# នីតិវិធីដាក់ពាក្យបណ្ដឹងលើការមិនអនុវត្តន៍តាមច្បាប់ Title VI

បុគ្គលណាដែលជឿជាក់ថាខ្លួនត្រូវបានរងគ្រោះដោយការរើសអើងខុសច្បាប់ពី TriMet ដោយសារតែពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើត អាចដាក់ពាក្យបណ្ដឹងបាន ដោយបំពេញនិងផ្ញើបែបបទនៃពាក្យបណ្ដឹងតវ៉ា Title VI របស់ TriMet។

TriMet ស៊ើបអង្កេតលើបណ្ដឹងដែលទទួលបានមិនអោយលើសពី 180 ថ្ងៃ បន្ទាប់ពីឧប្បត្តិហេតុដែលបានចោទប្រកាន់។ TriMet នឹងដំណើរលើពាក្យបណ្ដឹងណាដែលបំពេញគ្រប់ចំណុច។ នៅពេលដែលទទួលបានពាក្យបណ្ដឹងដែលបានបំពេញគ្រប់ចំណុច នោះTriMet នឹងពិនិត្យមើលវាឡើងវិញដើម្បីកំណត់ថាតើ TriMet មានយុត្តាធិការឬយ៉ាងណា។ អ្នកប្ដឹងតវ៉ានឹងទទួលបានលិខិតជម្រាបគាត់ថាតើបណ្ដឹងនេះនឹងត្រូវស៊ើបអង្កេតដោយ TriMet ដែរឬអត់។

ជាទូទៅ TriMet នឹងបញ្ចប់ការស៊ើបអង្កេតក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្ដឹងដែលបានបំពេញគ្រប់ចំណុច។ ប្រសិនបើត្រូវការព័ត៌មានបន្ថែមដើម្បីដោះស្រាយក្ដីនេះ TriMet ប្រហែលជាអាចទាក់ទងទៅអ្នកដាក់ពាក្យបណ្ដឹងតវ៉ាបាន។ លើកលែងតែ TriMet សុំពន្យាពេល បើមិនដូច្នោះទេអ្នកប្ដឹងតវ៉ានឹងមានពេលដប់ (10) ថ្ងៃគិតចាប់ពីថ្ងៃដែលគេផ្ញើលិខិតទៅ ដើម្បីបញ្ជូនព័ត៌មានដែលបានស្នើសុំទៅអ្នកស៊ើបអង្កេតក្ដីពី TriMet។

ប្រសិនបើអ្នកប្ដឹងតវ៉ាមិនបានទាក់ទង រឺក៏មិនផ្ដល់ព័ត៌មានបន្ថែមទៅអោយអ្នកស៊ើបអង្កេតក្ដីរបស់ TriMet នៅក្នុងពេលវេលាដែលតម្រូវនោះទេ TriMet អាចបិទក្ដីតវ៉ារដ្ឋបាលនេះបាន។ ក្ដីនេះអាចត្រូវបានគេបិទដោយរដ្ឋបាលផងដែរប្រសិនបើអ្នកប្ដឹងតវ៉ាមិនចង់បន្តរឿងក្ដីរបស់ខ្លួនតទៅទៀត។

បន្ទាប់ពីការស៊ើបអង្កេតបានបញ្ចប់រួចរាល់ TriMet នឹងចេញលិខិតមួយទៅអ្នកប្ដឹងតវ៉ា ដោយសង្ខេបលទ្ធផលនៃការស៊ើបអង្កេតដោយបញ្ជាក់ពីការរកឃើញនិងណែនាំអំពីវិធានការកែតម្រូវណាមួយដែលត្រូវធ្វើឡើង ដែលជាលទ្ធផលនៃការស៊ើបអង្កេតនោះ។ ប្រសិនបើអ្នកប្ដឹងតវ៉ាមិនយល់ស្របនឹងការសំរេចរបស់ TriMet នោះគាត់អាចស្នើសុំអោយមានការពិចារណាឡើងវិញ ដោយបញ្ជូនសំណើជាលាយលក្ខណ៍អក្សរទៅអគ្គនាយករបស់ TriMet ក្នុងរយៈពេលប្រាំពីរ (7) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃលិខិតរបស់ TriMet ដោយបញ្ជាក់ពីមូលដ្ឋានជាក់លាក់សម្រាប់ការសុំអោយគេពិចារណាឡើងវិញ។ អគ្គនាយកនឹងជូនដំណឹងដល់អ្នកប្ដឹងតវ៉ាអំពីការសម្រេចចិត្តរបស់គាត់ថាព្រមទទួល ឬបដិសេធសំណើសុំការពិចារណាឡើងវិញក្នុងរយៈពេល 10 ថ្ងៃ។ ក្នុងករណីដែលការសុំពិចារណាត្រូវបានផ្ដល់ជូន នោះអគ្គនាយកនឹងចេញលិខិតសំរេចទៅអ្នកប្ដឹងតវ៉ានៅពេលបញ្ចប់ការពិចារណាឡើងវិញ។

# បែបបទនៃពាក្យបណ្ដឹងតវ៉ា Title VI *

ច្បាប់ Title VI ស្ដីពីសិទ្ធិស៊ីវិលនាឆ្នាំ 1964 តម្រូវថា "គ្មាននរណាម្នាក់នៅក្នុងសហរដ្ឋអាមេរិក ដោយផ្អែកលើហេតុផលនៃពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើត នឹងត្រូវបានគេមិនអោយចូលរួម, បដិសេធជំនួយ ឬត្រូវទទួលរងនូវការរើសអើងក្នុងកម្មវិធីណាមួយ ឬសកម្មភាពណាមួយ ដែលកំពុងទទួលបានជំនួយហិរញ្ញវត្ថុពីសហព័ន្ធនោះឡើយ។"

ព័ត៌មានខាងក្រោមគឺចាំបាច់ដើម្បីជួយយើងក្នុងការដំណើរការបណ្ដឹងតវ៉ារបស់អ្នក។ ប្រសិនបើអ្នកត្រូវការជំនួយណាមួយក្នុងការបំពេញបែបបទនេះ ឬត្រូវការព័ត៌មានជាទម្រង់ផ្សេងទៀត សូមមេត្តាប្រាប់យើងផង។

បំពេញនិងផ្ញើបែបបទនេះទៅ TriMet, Civil Rights Investigator,
1800 SW 1st Ave., Suite 300, Portland, OR 97201។

1. ឈ្មោះអ្នកប្ដឹងតវ៉ា៖ ____________________

2. អាស័យដ្ឋាន៖ ____________________

3. ទីក្រុង៖ ____________ រដ្ឋ៖ ________ លេខកូដតំបន់៖ ________

4. លេខទូរស័ព្ទ (ផ្ទះ)៖ ____________ (ជំនួញ)៖ ____________

   អាសយដ្ឋានអ៊ីមែលអេឡិចត្រូនិក៖ ____________________

5. តើអ្នកដាក់ពាក្យបណ្ដឹងនេះក្នុងនាមខ្លួនឯងវឺ? ____________ បើមិនដូច្នោះទេសូមសរសេរឈ្មោះ និងថាតើអ្នកត្រូវជាអ្វីជាមួយបុគ្គលដែលអ្នកកំពុងតវ៉ាអោយ៖

   ____________________

   សូមពន្យល់ពីមូលហេតុដែលអ្នកដាក់ពាក្យសំរាប់ភាគីទីបី៖ ____________________

   ____________________

   ____________________

   សូមបញ្ជាក់ថាអ្នកបានទទួលការអនុញ្ញាតពីភាគីដែលរងគ្រោះ ប្រសិនបើអ្នក កំពុងដាក់ពាក្យក្នុងនាមភាគីទីបី។ ____________________

6. តើអ្វីដែលត្រូវជាងគេបំផុតក្នុងចំណោមហេតុផលខាងក្រោម ដែលពិពណ៌នាអំពីហេតុផលដែលអ្នកជឿជាក់ថាការរើសអើងបានកើតឡើង? តើមកពី (សូមគូសលើប្រអប់ណាមួយដែលត្រូវ)៖

   a. ជាតិសាសន៍៖ ☐ b. ពណ៌សម្បុរ៖ ☐ c. ដើមកំណើត៖ ☐

7. តើការរើសអើងដែលបានចោទប្រកាន់នេះ បានកើតឡើងនៅខែថ្ងៃឆ្នាំណាដែរ? ______________________

8. នៅក្នុងពាក្យផ្ទាល់ខ្លួនរបស់អ្នក សូមពិពណ៌នាអំពីការរើសអើងដែលបានចោទប្រកាន់។ ពន្យល់ពីអ្វីដែលបានកើតឡើង និងតើគោលនយោបាយ កម្មវិធី សកម្មភាព ឬជនណាមួយដែលអ្នកជឿថាមានការរើសអើងចំពោះអ្នក។

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

9. តើអ្នកមានដែលធ្លាប់បានដាក់ពាក្យបណ្តឹងនេះទៅស្ថាប័នសហព័ន្ធ រដ្ឋ ឬទីភ្នាក់ងារក្នុងតំបន់ណាផ្សេងទៀត រឺជាមួយតុលាការសហព័ន្ធ រឺតុលាការរដ្ឋដែររឺទេ?

មាន៖ ☐ មិនមានទេ៖ ☐

បើមាន សូមគូសលើប្រអប់នីមួយៗដែលត្រូវចំពោះអ្នក៖

ទីភ្នាក់ងារសហព័ន្ធ៖ ☐ តុលាការសហព័ន្ធ៖ ☐ ទីភ្នាក់ងាររដ្ឋ៖ ☐

តុលាការរដ្ឋ៖ ☐ ទីភ្នាក់ងារក្នុងតំបន់៖ ☐

10. ស ូ មផ្ តល់ន ូ វព័ត៌មានទំនាក់ទំនងរបស់ទីភ្ នាក់ងារ / តុ លាការ ដលែអ្ នកបានដាក់ពាក្ យ បណ្ តឹង។

ឈ្មោះ៖ ______________________________________________

អាស័យដ្ឋាន៖ ______________________________________________

ទីក្រុង៖ ______________ រដ្ឋ៖ __________ លេខកូដតំបន់៖ ______________

លេខទូរស័ព្ទ (ផ្ទះ)៖ ______________ (ជំនួញ)៖ ______________

អាសយដ្ឋានអ៊ីមែលអេឡិចត្រូនិក៖______________________________________

11. ស ូ មចុះហត្ ថលេខាខាងក្ រោម។ អ្ នកអាចភ្ ជាប់ឯកសារ ឬព័ត៌មានផ្ សេងទៀតជាលាយលក្ ខណ៍អក្ សរ ដលែអ្ នកគិតថាពាក់ព័ន្ ធនឹងបណ្ តឹងតវ៉ារបស់អ្ នក។

______________________________ ______________________________

ហត្ថលេខារបស់អ្នកប្តឹងតវ៉ា កាលបរិច្ឆេទ